**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៩៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារ នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៣៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង ស្ថាប័នថវិកាកម្មវិធី
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.–**

ត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលចែកជាមុខងារ អនុមុខងារ និងអនុអនុមុខងារ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.–**

អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចរៀបចំបង្កើតបន្ថែមនូវលេខកូដចំណាត់ថ្នាក់មុខងារតាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំ នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ហើយនៅចុងឆ្នាំនីមួយៗ ត្រូវរៀបចំប្រកាសបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់មុខងារដែលបានបង្កើតបន្ថែម ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងចុះហត្ថលេខាលើប្រកាសបំពេញបន្ថែម។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.–**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៧ ឆ្នាំ២០១៧

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:-**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  *“ដើម្បីជូនជ្រាប”*
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
  *“ដើម្បីអនុវត្ត”*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៥៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

## ចំណាត់ថ្នាក់មុខងារ នៃមាតិកាថវិកា

| កូដមុខងារ | កូដអនុមុខងារ | កូដអនុអនុមុខងារ | បរិយាយ | សេចក្ដីពន្យល់ |
|---|---|---|---|---|
| ៧០១ | | | សេវាកម្មសាធារណៈទូទៅ | |
| | ៧០១១ | | អង្គនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ កិច្ចការហិរញ្ញវត្ថុ សារពើពន្ធ និងកិច្ចការបរទេស | |
| | | ៧០១១១ | អង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្ររបស់អង្គនីតិប្បញ្ញត្តិ ដែលពុំអាចកំណត់មុខងារជាក់លាក់ ដូចជា÷ ក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ល។ អង្គនីតិប្រតិបត្តិ ដែលពុំអាចកំណត់មុខងារជាក់លាក់ ដូចជា÷ ក្រសួងព្រះបរមរាជវាំង ធនាគារជាតិ នៃកម្ពុជា ទីស្ដីការគណៈរដ្ឋមន្ត្រី សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ល។ រួមទាំងទីប្រឹក្សាផ្នែករដ្ឋបាល និងនយោបាយអមអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ<br>+មិនរាប់បញ្ចូល÷ ការិយាល័យថ្នាក់ដឹកនាំក្រសួង ស្ថាប័ន គណៈកម្មាធិការអន្តរក្រសួង ជាដើម ដែលអាចកំណត់មុខងារជាក់លាក់ (បែងចែកទៅតាមចំណាត់ថ្នាក់មុខងារ)។ |
| | | ៧០១១២ | កិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធ | -ការគ្រប់គ្រងកិច្ចការ សេវាហិរញ្ញវត្ថុ និងសារពើពន្ធ, ការគ្រប់គ្រងមូលនិធិសាធារណៈ និងបំណុលសាធារណៈ, ដំណើរការនៃផែនការប្រមូលពន្ធ, ដំណើរការសេវាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អាជ្ញាធរប្រមូលចំណូល អង្គភាពរៀបចំថវិកា......), សេវាគណនេយ្យ និងសវនកម្ម ដូចជា÷ អាជ្ញាធរសវនកម្មជាតិ ក្រុមប្រឹក្សាជាតិគណនេយ្យ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីកិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធ<br>+រួមបញ្ចូលទាំង÷ កិច្ចការ សេវាហិរញ្ញវត្ថុ និងសារពើពន្ធនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>+មិនរួមបញ្ចូល÷ ការទូទាត់ការប្រាក់ ការធានាទិញមូលប័ត្របំណុលរបស់រាជរដ្ឋាភិបាល និងការសង |

| | | | | |
|---|---|---|---|---|
| | | | | ប្រាក់ដើម ដែលបានកំណត់នៅក្នុង ៧០១៧០, ការត្រួតពិនិត្យវិស័យធនាគារ ដែលបានកំណត់នៅក្នុង ៧០៤១១។ |
| | | ៧០១១៣ | កិច្ចការបរទេស | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងកិច្ចការបរទេស ដំណើរការ ការគាំទ្រ ក្រសួងការ-បរទេស និងសហប្រតិបត្តិការអន្តរជាតិ បេសកកម្មកុងស៊ុល ការិយាល័យប្រចាំអង្គការអន្តរជាតិ បណ្ណាល័យ ការិយាល័យដែលបម្រើឱ្យវប្បធម៌ និងព័ត៌មាន ដែលមានទីតាំងនៅក្រៅប្រទេស ការបង់វិភាគទានដល់អង្គការអន្តរជាតិនានា<br>+មិនរួមបញ្ចូល÷ ជំនួយផ្នែកសេដ្ឋកិច្ចទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច ដែលបានកំណត់នៅក្នុង ៧០១២១, បេសកកម្មជំនួយផ្នែកសេដ្ឋកិច្ចទៅរដ្ឋាភិបាលក្រៅប្រទេស ដែលបានកំណត់នៅក្នុង ៧០១២១, ការចូលរួមចំណែកតាមលទ្ធភាពទៅក្នុងកម្មវិធីជំនួយដល់អង្គការអន្តរជាតិ ឬ តំបន់ ដែលបានកំណត់នៅក្នុង ៧០១២២, អង្គភាពយោធាប្រចាំការនៅក្រៅប្រទេស ដែលបានកំណត់នៅក្នុង ៧០២១០, ជំនួយយោធាទៅក្រៅប្រទេស ដែលបានកំណត់នៅក្នុង ៧០២៣០, កិច្ចការសេដ្ឋកិច្ច និងពាណិជ្ជកម្មបរទេស ដែលបានកំណត់នៅក្នុង ៧០៤១១, កិច្ចការ និងសេវាកម្មទេសចរណ៍ ដែលបានកំណត់នៅក្នុង ៧០៤៧៣។ |
| | ៧០១២ | | ជំនួយសេដ្ឋកិច្ចទៅក្រៅប្រទេស | |
| | | ៧០១២១ | ជំនួយសេដ្ឋកិច្ចទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច ដំណើរការ ការគាំទ្រ នៃកម្មវិធីជំនួយបច្ចេកទេស កម្មវិធីបណ្តុះបណ្តាល និងអាហារូបករណ៍។ ហិរញ្ញប្បទានឥតសំណងផ្នែកសេដ្ឋកិច្ច អាចជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់ ឬ ហិរញ្ញប្បទានសហប្រតិបត្តិការដោយមិនមានការប្រាក់<br>+មិនរាប់បញ្ចូល÷ ការចូលរួមចំណែកតាមលទ្ធភាពទៅក្នុងកម្មវិធីជំនួយដល់អង្គការអន្តរជាតិ ឬ តំបន់ ដែលបានកំណត់នៅក្នុង ៧០១២២ ជំនួយយោធាទៅក្រៅប្រទេស ដែលបានកំណត់នៅក្នុង ៧០២៣០។ |
| | | ៧០១២២ | ជំនួយសេដ្ឋកិច្ចតាមរយៈអង្គការអន្តរជាតិ | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងជំនួយសេដ្ឋកិច្ចតាមរយៈអង្គការអន្តរជាតិ។ វិភាគទានអាចជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់ដល់មូលនិធិអភិវឌ្ឍសេដ្ឋកិច្ច ដែលគ្រប់គ្រងដោយអង្គការអន្តរជាតិក្នុងតំបន់ ឬ អង្គការផ្សេងៗទៀត |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ ជំនួយសម្រាប់ដំណើរការរក្សាសន្តិភាពអន្តរជាតិ ដែលបានកំណត់នៅក្នុង៧០២៣០។ |
| ៧០១៣ | | | សេវាកម្មទូទៅ | សេវាកម្មទូទៅនេះ គ្របដណ្តប់លើសេវាកម្មទូទៅដែលមិនបម្រើឱ្យមុខងារជាក់លាក់ណាមួយ។ |
| | ៧០១៣១ | | សេវាបុគ្គលិកទូទៅ | -ការគ្រប់គ្រង និងដំណើរការនៃសេវាបុគ្គលិកទូទៅ រួមមានការរៀបចំ និងការអនុវត្តគោលនយោបាយបុគ្គលិកទូទៅ នីតិវិធីនៃការជ្រើសរើស ការដំឡើងឋានៈ ការរៀបចំតួនាទីនិងភារកិច្ច ការវាយតម្លៃ។ល។<br>+មិនរាប់បញ្ចូល÷ ការគ្រប់គ្រង និងសេវាផ្នែកបុគ្គលិក ដែលត្រូវបានកំណត់តាមមុខងារជាក់លាក់។ |
| | ៧០១៣២ | | សេវាផែនការ និងស្ថិតិ | -ការគ្រប់គ្រង និងដំណើរការនៃសេវាផែនការ និងស្ថិតិរួមមាន ការរៀបចំ ការសម្របសម្រួល ការពិនិត្យតាមដាន និងផ្សព្វផ្សាយផែនការសេដ្ឋកិច្ច សង្គម និងស្ថិតិ<br>+មិនរាប់បញ្ចូល÷ ផែនការសេដ្ឋកិច្ច សង្គម និងស្ថិតិ ដែលត្រូវបានកំណត់តាមមុខងារជាក់លាក់។ |
| | ៧០១៣៣ | | សេវាទូទៅផ្សេងៗទៀត | ការគ្រប់គ្រង និងសេវាទូទៅ ពាក់ព័ន្ធនឹងសេវាកម្មទូទៅ ហើយមិនបានកំណត់ក្នុង ៧០១៣១ និង ៧០១៣២<br>+មិនរួមបញ្ចូល÷ សេវាទូទៅដទៃផ្សេងទៀតដែលជាប់ពាក់ព័ន្ធនឹងមុខងារជាក់លាក់ ដែលបានបែងចែកទៅតាមមុខងារ។ |
| ៧០១៤ | | | ការស្រាវជ្រាវជាមូលដ្ឋាន | ការស្រាវជ្រាវជាមូលដ្ឋាន គឺជាការពិសោធន៍ផ្នែកទ្រឹស្តី ឬ ការអនុវត្តន៍ ដែលត្រូវបានធ្វើឡើងជាបឋមដើម្បីទទួលបានចំណេះដឹងថ្មីជាមូលដ្ឋានគ្រឹះ។ |
| | ៧០១៤០ | | ការស្រាវជ្រាវជាមូលដ្ឋាន | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការស្រាវជ្រាវជាមូលដ្ឋាន<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវជាមូលដ្ឋាន ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាលដូចជា វិទ្យាស្ថានស្រាវជ្រាវ ឬ សាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវ និងការពិសោធន៍ ដែលមានមុខងារច្បាស់លាស់។ |
| ៧០១៥ | | | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសេវាកម្មសាធារណៈទូទៅ | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសេវាសាធារណៈទូទៅ ដើម្បីសម្រេចគោលដៅជាក់លាក់ ដូចជា÷ ផលិតសម្ភារ និងឧបករណ៍ថ្មីៗ ដើម្បីពង្រឹងគុណភាពសេវា។ |

| | | | | |
|---|---|---|---|---|
| | | ៧០១៥០ | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសេវាកម្មសាធារណៈទូទៅ | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីសម្រេចគោលដៅសេវាសាធារណៈទូទៅ<br>-ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសេវាសាធារណៈទូទៅ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ ឬ សាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០១៦ | | សេវាកម្មសាធារណៈទូទៅផ្សេងៗ | |
| | | ៧០១៦០ | សេវាកម្មសាធារណៈទូទៅផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងសេវាកម្មសាធារណៈទូទៅផ្សេងៗ ដូចជា÷ ការចុះបញ្ជីអ្នកបោះឆ្នោត ការរៀបចំការបោះឆ្នោត ការធ្វើប្រជាមតិ។ល។<br>+រួមបញ្ចូលទាំង÷ សេវាសាធារណៈទូទៅដែលមិនអាចកំណត់នៅក្នុង ៧០១១, ៧០១២, ៧០១៣, ៧០១៤, ឬ ៧០១៥<br>+មិនរួមបញ្ចូល÷ ប្រតិបត្តិការបំណុលសាធារណៈ ដែលបានកំណត់នៅក្នុង ៧០១៧; ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុង ៧០១៨។ |
| | ៧០១៧ | | ប្រតិបត្តិការបំណុលសាធារណៈ | |
| | | ៧០១៧០ | ប្រតិបត្តិការបំណុលសាធារណៈ | -ការទូទាត់ការប្រាក់ ការធានាទិញមូលប័ត្របំណុលរបស់រដ្ឋ និងការសងប្រាក់ដើម<br>+មិនរួមបញ្ចូល÷ចំណាយរដ្ឋបាលនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលបានកំណត់នៅក្នុង ៧០១១២។ |
| | ៧០១៨ | | ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | |
| | | ៧០១៨០ | ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | -ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈទូទៅ និងមិនអាចកំណត់មុខងារជាក់លាក់។ |

| | | | | |
|---|---|---|---|---|
| ៧០២ | | | ការការពារជាតិ | |
| | ៧០២១ | | ការការពារជាតិផ្នែកយោធា | |
| | | ៧០២១០ | ការការពារជាតិផ្នែកយោធា | -ការគ្រប់គ្រង និងសេវាការពារជាតិផ្នែកយោធា ពាក់ព័ន្ធនឹងដំណើរការ ការគាំទ្រកម្លាំងយោធាជើងគោក ជើងទឹក ជើងអាកាស វិស្វកម្ម ដឹកជញ្ជូន ទំនាក់ទំនង ចារកម្ម និងកងកម្លាំងគាំទ្រផ្សេងទៀត<br>+រួមបញ្ចូលទាំង÷ការិយាល័យសេនាធិការប្រចាំការនៅក្រៅប្រទេស មន្ទីរពេទ្យយោធាតាមភូមិភាគ និងមូលដ្ឋាន<br>+មិនរួមបញ្ចូល÷ បេសកកម្មជំនួយយោធាបរទេស ដែលបានកំណត់នៅក្នុង ៧០២៣០ មន្ទីរពេទ្យ និងមណ្ឌលសុខភាព ដែលបានកំណត់នៅក្នុង ៧០៧៣ សាលា និងមហាវិទ្យាល័យយោធា ដែលមានកម្មវិធីសិក្សាស្រដៀងគ្នាទៅនឹងគ្រឹះស្ថានបណ្តុះបណ្តាលស៊ីវិល បើទោះជាអ្នកចូលរួមកំណត់ត្រឹមមន្ត្រីយោធា និងក្រុមគ្រួសារយោធា ដែលបានកំណត់នៅក្នុង ៧០៩១, ៧០៩២, ៧០៩៣ ឬ ៧០៩៤ និងប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីយោធា ៧១០២។ |
| | ៧០២២ | | ការការពារជាតិផ្នែកស៊ីវិល | |
| | | ៧០២២០ | ការការពារជាតិផ្នែកស៊ីវិល | -ការគ្រប់គ្រង និងសេវាការពារជនស៊ីវិល ពាក់ព័ន្ធនឹងការរៀបចំផែនការ ការហ្វឹកហ្វឺន ដំណើរការ ឬការគាំទ្រកងកម្លាំងសម្រាប់ការពារជនស៊ីវិល ដើម្បីទប់ទល់ហេតុការណ៍ដែលអាចកើតមានឡើងជាយថាហេតុ<br>+មិនរួមបញ្ចូល÷ សេវាអគ្គិភ័យសម្រាប់ការពារជនស៊ីវិល ដែលបានកំណត់នៅក្នុង ៧០៣២០ ការទិញការស្តុកស្បៀងអាហារ ឧបករណ៍ និងសម្ភារផ្សេងៗ សម្រាប់ប្រើប្រាស់បន្ទាន់ជួយជនស៊ីវិល ក្នុងករណីមានគ្រោះមហន្តរាយកើតឡើង ដែលបានកំណត់នៅក្នុង ៧១០៩០។ |
| | ៧០២៣ | | ជំនួយយោធាទៅក្រៅប្រទេស | |

| | | | | |
|---|---|---|---|---|
| | | ៧០២៣០ | ជំនួយយោធាទៅក្រៅប្រទេស | -ការគ្រប់គ្រង ដំណើរការបេសកកម្មនិងជំនួយផ្នែកយោធា ពីរដ្ឋាភិបាលទៅអង្គការ ឬ សម្ព័ន្ធយោធាអន្តរជាតិ<br>-ជំនួយបរទេសផ្នែកយោធាអាចជា ហិរញ្ញប្បទានសហប្រតិបត្តិការមិនមានការប្រាក់ ឬ ហិរញ្ញប្បទានសហ-ប្រតិបត្តិការផ្នែកសម្ភារ ដល់កងកម្លាំងរក្សាសន្តិភាពអន្តរជាតិ រួមទាំងការបណ្តុះបណ្តាលកងកម្លាំងផងដែរ។ |
| | ៧០២៤ | | ការស្រាវជ្រាវ និងអភិវឌ្ឍការការពារជាតិ | |
| | | ៧០២៤០ | ការស្រាវជ្រាវ និងអភិវឌ្ឍការការពារជាតិ | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការការពារជាតិ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកការការពារជាតិ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ ឬ សាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០២៥ | | ការការពារជាតិផ្សេងៗ | |
| | | ៧០២៥០ | ការការពារជាតិផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការការពារជាតិ ហើយមិនបានកំណត់ក្នុង ៧០២១,៧០២២, ៧០២៣, ឬ ៧០២៤<br>+មិនរួមបញ្ចូល÷ ការគ្រប់គ្រងការងារអតីតយុទ្ធជនសង្គ្រាម ដែលបានកំណត់នៅក្នុង ៧១០២។ |
| ៧០៣ | | | សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ | |
| | ៧០៣១ | | សេវានគរបាល | |
| | | ៧០៣១០ | សេវានគរបាល | -ការគ្រប់គ្រង និងសេវានគរបាល ពាក់ព័ន្ធនឹងការចុះបញ្ជីជនបរទេស ការចេញឯកសារការងារ និងធ្វើដំណើរឱ្យជនអន្តោប្រវេសន៍ ការរក្សាទុកនូវរាល់ឯកសារនៃការគ្រប់គ្រងប្រជាពលរដ្ឋ ការរៀបចំនិងត្រួតពិនិត្យបទប្បញ្ញត្តិចរាចរណ៍ផ្លូវគោក ការទប់ស្កាត់ការរត់ពន្ធ និងការទប់ស្កាត់បទល្មើសនេសាទជាដើម<br>-ប្រតិបត្តិការនៃកងកម្លាំងនគរបាលទូទៅ ការគាំទ្រកម្មវិធីបណ្តុះបណ្តាល ឬ ដំណើរការមន្ទីរពិសោធន៍របស់នគរបាល<br>+រួមបញ្ចូលទាំង÷ នគរបាលចរាចរណ៍ |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ សាលានគរបាល ដែលផ្តល់ការអប់រំទូទៅបន្ថែមលើការបណ្តុះបណ្តាលនគរបាលដែលបាន កំណត់នៅក្នុង ៧០៩១,៧០៩២, ៧០៩៣ ឬ ៧០៩៤។ |
| | ៧០៣២ | | សេវាការពារអគ្គិភ័យ | |
| | | ៧០៣២០ | សេវាការពារអគ្គិភ័យ | -ការគ្រប់គ្រង និងសេវា ពាក់ព័ន្ធនឹងការការពារ ការពន្លត់ ឬ កម្មវិធីបណ្តុះបណ្តាលការពន្លត់អគ្គិភ័យ<br>+រួមបញ្ចូលទាំង÷ សេវាការពារជនរងគ្រោះ ដូចជាការជួយសង្គ្រោះប្រជាជននៅតំបន់ភ្នំ តំបន់ឆ្នេរខ្សាច់ តំបន់ទឹកជំនន់។ល។<br>+មិនរួមបញ្ចូល÷ ការការពារជនស៊ីវិល ដែលបានកំណត់នៅក្នុង ៧០២២០ ការបណ្តុះបណ្តាល និង បំពាក់សម្ភារសម្រាប់កងកម្លាំងបង្ការ និងពន្លត់ភ្លើងឆេះព្រៃ ដែលបានកំណត់នៅក្នុង ៧០៤២២។ |
| | ៧០៣៣ | | តុលាការ | |
| | | ៧០៣៣០ | តុលាការ | -ការគ្រប់គ្រង ដំណើរការ ការគាំទ្រ តុលាការស៊ីវិល(រដ្ឋប្បវេណី និងព្រហ្មទណ្ឌ) និងប្រព័ន្ធយុត្តិធម៌ រួមមាន÷ ការអនុវត្តការផាកពិន័យ ការដោះស្រាយតាមផ្លូវច្បាប់ ដែលសម្រេចដោយតុលាការ ដំណើរការដោះលែង និងការព្យួរទោសដោយមានលក្ខខណ្ឌ<br>-ការផ្តល់ប្រឹក្សា ឬ តំណាងផ្នែកច្បាប់ក្នុងនាមរដ្ឋាភិបាល ឬ ភាគីផ្សេងៗ ដែលផ្តល់ដោយរដ្ឋាភិបាលជា សាច់ប្រាក់ ឬ សេវាកម្មផ្លូវច្បាប់<br>+រួមបញ្ចូលទាំង÷ សាលាក្តីរដ្ឋបាល ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងអង្គភាពប្រហាក់ប្រហែល<br>+មិនរួមបញ្ចូល÷ រដ្ឋបាលពន្ធនាគារ ដែលបានកំណត់នៅក្នុង ៧០៣៤០។ |
| | ៧០៣៤ | | ពន្ធនាគារ | |
| | | ៧០៣៤០ | ពន្ធនាគារ | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រពន្ធនាគារ និងកន្លែងផ្សេងទៀតសម្រាប់ការឃុំខ្លួន ឬ ការស្តារសម្បទា ដូចជា÷ កសិដ្ឋាន រោងជាង មណ្ឌលកែប្រែ និងមជ្ឈមណ្ឌលសម្រាប់ជនវិកលចរិត ដែលបានប្រព្រឹត្ត បទល្មើស។ល។ |
| | ៧០៣៥ | | ការស្រាវជ្រាវ និងអភិវឌ្ឍសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ | |

| | | | | |
|---|---|---|---|---|
| | | ៧០៣៥០ | ការស្រាវជ្រាវ និងអភិវឌ្ឍសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ | -កិច្ចការដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ និងអភិវឌ្ឍសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ដែលផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងសាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០៣៦ | | សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈផ្សេងៗ | |
| | | ៧០៣៦០ | សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការងារសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ដែលមិនបានកំណត់ក្នុង ៧០៣១, ៧០៣២, ៧០៣៣, ៧០៣៤ ឬ ៧០៣៥។ |
| ៧០៤ | | | សេដ្ឋកិច្ច | |
| | ៧០៤១ | | សេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និងការងារ | |
| | | ៧០៤១១ | សេដ្ឋកិច្ចទូទៅ និងពាណិជ្ជកម្ម | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម<br>-បទប្បញ្ញត្តិ ឬ ការគាំទ្រសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដូចជាការជំរុញពាណិជ្ជកម្ម, ការនាំចេញ និងការនាំចូល។ល។<br>-ប្រតិបត្តិការ ឬ ការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធនឹងប្រកាសនីយប័ត្រ ពាណិជ្ជសញ្ញា សិទ្ធិថតចម្លង ការចុះបញ្ជីក្រុមហ៊ុន ការព្យាករអាកាសធាតុ បទដ្ឋាន ការវាស់ស្ទង់នីវ៉ូទឹក ការវាស់ផ្ទៃក្រឡាដី ការត្រួតពិនិត្យវិស័យធនាគារ។ល។<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីលើកស្ទួយគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច និងពាណិជ្ជកម្ម<br>+រួមបញ្ចូលទាំង÷ ការអប់រំ និងការការពារអ្នកប្រើប្រាស់ដូចជាការពង្រឹង និងការត្រួតពិនិត្យការផ្ដល់អាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រសម្រាប់ការនាំចេញ ការនាំចូលតាមច្បាប់ និងបទប្បញ្ញត្តិពិពិធកម្មទីផ្សារ និងអភិវឌ្ឍវិស័យឯកជន។ល។ |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ កិច្ចការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានកំណត់នៅក្នុង ៧០៤២ និងឧស្សាហកម្មផ្សេងៗ ដែលបានកំណត់នៅក្នុង ៧០៤៧។ |
| | | ៧០៤១២ | ការងារ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយការងារ, ការត្រួតពិនិត្យ លក្ខខណ្ឌការងារ ដូចជា÷ ចំនួនម៉ោងធ្វើការ ប្រាក់ខែ សុវត្ថិភាពការងារ។ល។<br>-ប្រតិបត្តិការ ឬ ការគាំទ្រកម្មវិធីទូទៅ ដើម្បីសម្របសម្រួលការងារ សំដៅកាត់បន្ថយការរើសអើងពូជសាសន៍ ភេទ អាយុ  ឈានទៅកាត់បន្ថយអត្រាគ្មានការងារធ្វើ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ដូចជា÷ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីការងារជាដើម<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីលើកស្ទួយគោលនយោបាយ និងកម្មវិធីការងារទូទៅ<br>+មិនរួមបញ្ចូល÷ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ  ដែលបានកំណត់នៅក្នុង ៧០៤២, ឧស្សាហកម្មផ្សេងៗ ដែលបានកំណត់នៅក្នុង ៧០៤៧ និងផ្តល់ការគាំពារពីសង្គមក្នុងទម្រង់ជាអត្ថប្រយោជន៍សាច់ប្រាក់ និងអត្ថប្រយោជន៍ជាសម្ភារ ចំពោះបុគ្គលដែលមិនមានការងារធ្វើ ដែលបានកំណត់នៅក្នុង ៧១០៥០។ |
| | ៧០៤២ | | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| | | ៧០៤២១ | កសិកម្ម | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការងារកសិកម្ម ឬ ការពង្រីកផ្ទៃដីដែលអាចដាំដុះបាន កំណែទម្រង់ការបែងចែកដីធ្លីកសិកម្ម និងការតាំងទីលំនៅលើដីកសិកម្ម<br>-ការសាងសង់ ឬដំណើរការប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធស្រោចស្រព និងការការពារគ្រោះទឹកជំនន់ រួមទាំងហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់ការងារនេះ<br>-ដំណើរការ ឬ ការគាំទ្រកម្មវិធីកសិកម្ម ដើម្បីរក្សាតុល្យភាព ឬ លើកកម្ពស់តម្លៃលើផលិតផលកសិកម្ម និងប្រាក់ចំណូលពីការធ្វើកសិកម្ម<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីកិច្ចការ និងសេវាកសិកម្ម<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពកសិកម្ម<br>+មិនរួមបញ្ចូល÷ គម្រោងអភិវឌ្ឍន៍ពហុគោលបំណង ដែលបានកំណត់នៅក្នុង ៧០៤៧៤។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤២២ | ព្រៃឈើ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យលើអាជីវកម្មព្រៃឈើ<br>-ដំណើរការ ឬ ការគាំទ្រលើការងារដាំដុះព្រៃឈើឡើងវិញ ការការពារសត្វល្អិត និងជំងឺឆ្លង សេវាពន្លត់ និងបង្ការភ្លើងឆេះព្រៃ និងផ្តល់សេវាជូនអ្នកអភិរក្សព្រៃឈើ។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីព្រៃឈើ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពព្រៃឈើ<br>+រួមបញ្ចូលទាំង÷ ការដាំព្រៃឈើបន្ថែម។ |
| | | ៧០៤២៣ | ការនេសាទ និងប្រមាញ់ | -ការនេសាទ និងការប្រមាញ់ជាលក្ខណៈពាណិជ្ជកម្ម និងជាលក្ខណៈកីឡា ដែលនៅក្រៅឧទ្យានជាតិ និងតំបន់អភិរក្សព្រៃឈើ<br>-ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យលើអាជីវកម្មនេសាទ និងការប្រមាញ់<br>-ដំណើរការ ឬការគាំទ្រទីកន្លែងភ្ញាស់ត្រី ទីកន្លែងសត្តឃាត។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីកិច្ចការ និងសេវានេសាទ និងការប្រមាញ់<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពនេសាទ និងការប្រមាញ់<br>+មិនរួមបញ្ចូល÷ ការការពារការនេសាទនៅដែនសមុទ្រ ដែលបានកំណត់នៅក្នុង ៧០៣១០ ការការពារប្រព័ន្ធជីវៈចម្រុះ និងដែនទេសភាព ដែលបានកំណត់នៅក្នុង ៧០៥៤០។ |
| | ៧០៤៣ | | ឥន្ទនៈ និងថាមពល | |

| | | | | |
|---|---|---|---|---|
| | | ៧០៤៣១ | រ៉ែថ្មងថ្ម និងរ៉ែប្រេងរឹង | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរុករក ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មធនធានរ៉ែថ្មងថ្ម និងរ៉ែប្រេងរឹងដែលអាចឆេះ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្ដីពីកិច្ចការសេវារ៉ែថ្មងថ្ម និងរ៉ែប្រេងរឹង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពរ៉ែថ្មងថ្ម និងរ៉ែប្រេងរឹង<br>+មិនរួមបញ្ចូល÷ ការដឹកជញ្ជូនរ៉ែថ្មងថ្ម និងរ៉ែប្រេងរឹង ដែលបានកំណត់នៅក្នុង ៧០៤៥។ |
| | | ៧០៤៣២ | តេលសិលា និងឧស្ម័នធម្មជាតិ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរុករក ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មធនធានតេលសិលា និងឧស្ម័នធម្មជាតិ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីកិច្ចការសេវាតេលសិលា និងឧស្ម័នធម្មជាតិ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពទាញយកតេលសិលា និងឧស្ម័នធម្មជាតិ<br>+មិនរួមបញ្ចូល÷ ការដឹកជញ្ជូនតេលសិលា ឬ ឧស្ម័នធម្មជាតិ ដែលបានកំណត់នៅក្នុង ៧០៤៥។ |
| | | ៧០៤៣៣ | ឥន្ធនៈនុយក្លេអ៊ែរ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរុករក ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មឥន្ធនៈនុយក្លេអ៊ែរ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីកិច្ចការសេវាឥន្ធនៈនុយក្លេអ៊ែរ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់សកម្មភាពទាញយកឥន្ធនៈនុយក្លេអ៊ែរ<br>+មិនរួមបញ្ចូល÷ កិច្ចការដឹកជញ្ជូនឥន្ធនៈនុយក្លេអ៊ែរ ដែលបានកំណត់នៅក្នុង ៧០៤៥ ការគ្រប់គ្រងកាកសំណល់សារធាតុវិទ្យុសកម្ម ដែលបានកំណត់នៅក្នុង ៧០៥១០។ |
| | | ៧០៤៣៤ | ឥន្ធនៈផ្សេងៗ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងឥន្ធនៈផ្សេងៗដូចជា÷ អាល់កុល ឈើ កាកសំណល់ឈើ ជីវឧស្ម័ន។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីការផលិត និងការប្រើប្រាស់ឥន្ធនៈទាំងនេះ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីបង្កើនការប្រើប្រាស់ឥន្ធនៈទាំងអស់នេះសម្រាប់ផលិតកម្មថាមពល<br>+មិនរួមបញ្ចូល÷ ការគ្រប់គ្រងព្រៃឈើ ដែលបានកំណត់នៅក្នុង ៧០៤២២។ ខ្យល់ និងកម្ដៅ |

| | | | | |
|---|---|---|---|---|
| | | | | ព្រះអាទិត្យ ដែលបានកំណត់នៅក្នុង ៧០៤៣៥ ឬ ៧០៤៣៦ ប្រភពកម្ដៅផែនដី ដែលបានកំណត់នៅក្នុង ៧០៤៣៦។ |
| | | ៧០៤៣៥ | អគ្គិសនី | ប្រភពនៃអគ្គិសនី ដូចជា÷ ខ្យល់ កម្ដៅព្រះអាទិត្យ វារីអគ្គិសនី។ល។<br>-ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មអគ្គិសនី ការបញ្ជូននិងការចែកចាយថាមពលអគ្គិសនី<br>-ការសាងសង់ ឬ ដំណើរការប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្ដីពីកិច្ចការសេវាអគ្គិសនី<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី រួមទាំងដើមទុនៈលើការសាងសង់ទំនប់វារីអគ្គិសនី និងកិច្ចការផ្សេងៗទៀត ដែលត្រូវបានរៀបចំឡើងដើម្បីផ្គត់ផ្គង់អគ្គិសនី<br>+មិនរួមបញ្ចូល÷ ថាមពលមិនមែនអគ្គិសនីផលិតដោយកម្លាំងខ្យល់ ឬ កម្ដៅព្រះអាទិត្យ ដែលបានកំណត់នៅក្នុង ៧០៤៣៦។ |
| | | ៧០៤៣៦ | ថាមពលមិនមែនអគ្គិសនី | ប្រភពនៃថាមពលមិនមែនអគ្គិសនី ដូចជា÷ ចំហាយទឹក ទឹកក្ដៅ ឬ ខ្យល់ក្ដៅ។ល។<br>-ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មសមស្របនៃថាមពលមិនមែនអគ្គិសនី<br>-ការសាងសង់ ឬ ដំណើរការប្រព័ន្ធផ្គត់ផ្គង់ថាមពលមិនមែនអគ្គិសនី<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្ដីពីថាមពលមិនមែនអគ្គិសនី<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីលើកកម្ពស់ការប្រើប្រាស់ថាមពលមិនមែនអគ្គិសនី<br>+រួមបញ្ចូលទាំង÷ ថាមពលមិនមែនអគ្គិសនីមានប្រភពមកពីកម្ដៅនៅក្នុងផែនដី កម្លាំងខ្យល់ ឬ កម្ដៅព្រះអាទិត្យ។ |
| | ៧០៤៤ | | រ៉ែក្រៅពីឥន្ធនៈ ការផលិត និងសំណង់ | |

| | | | | |
|---|---|---|---|---|
| | | ៧០៤៤១ | រ៉ែក្រៅពីឥន្ធនៈ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការជីករករ៉ែ និងធនធានរ៉ែ ដូចជារ៉ែមាស រ៉ែដែក ខ្សាច់ ដី ឥដ្ឋ ថ្ម ត្បូង ម្នាងសិលា។ល។ ការអភិរក្ស ការរុករក ការវិវត្ត ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យអាជីវកម្មធនធានរ៉ែ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីអាជីវកម្មរ៉ែ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីលើកកម្ពស់សកម្មភាពជីកយករ៉ែ<br>+រួមបញ្ចូលទាំង÷ ការចេញលិខិតអនុញ្ញាត កិច្ចសន្យាជួល និងបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងអាជីវកម្មរ៉ែ<br>+មិនរួមបញ្ចូល÷ រ៉ែត្បូងថ្ម និងរ៉ែប្រេងរឹង ដែលបានកំណត់នៅក្នុង ៧០៤៣១ គេលសិលា និងឧស្ម័នធម្មជាតិ ដែលបានកំណត់នៅក្នុង ៧០៤៣២ និងឥន្ធនៈនុយក្លេអ៊ែរ ដែលបានកំណត់នៅក្នុង ៧០៤៣៣។ |
| | | ៧០៤៤២ | ផលិតកម្ម | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យផលិតកម្ម<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីផលិតកម្ម<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីលើកកម្ពស់ផលិតកម្ម<br>+រួមបញ្ចូលទាំង÷ ការត្រួតពិនិត្យសុវត្ថិភាពផលិតកម្ម, ការការពារអ្នកប្រើប្រាស់ប្រឆាំងនឹងផលិតផលមានគ្រោះថ្នាក់<br>+មិនរួមបញ្ចូល÷ រ៉ែត្បូងថ្ម និងរ៉ែប្រេងរឹង (ដែលបានកំណត់នៅក្នុង ៧០៤៣១) គេលសិលា និងឧស្ម័នធម្មជាតិ ដែលបានកំណត់នៅក្នុង ៧០៤៣២ ឬ ឥន្ធនៈនុយក្លេអ៊ែរ ដែលបានកំណត់នៅក្នុង ៧០៤៣៣។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤៤៣ | សំណង់ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យសំណង់<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីសំណង់<br>+រួមបញ្ចូលទាំង÷ ការចេញវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ការពិនិត្យការដ្ឋានសំណង់ ដើម្បីឱ្យស្របតាមបញ្ញត្តិស្តីពីសុវត្ថិភាព។ល។<br>+មិនរួមបញ្ចូល÷ ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធនសម្រាប់ការសង់អគារឧស្សាហកម្ម ផ្លូវ ទីសាធារណៈ អគារវប្បធម៌។ល។ និងអភិវឌ្ឍលំនៅដ្ឋាន ដែលបានកំណត់នៅក្នុង ៧០៦១០។ |
| | ៧០៤៥ | | ការដឹកជញ្ជូន | |
| | | ៧០៤៥១ | ការដឹកជញ្ជូនតាមផ្លូវគោក | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការប្រើប្រាស់ និងការថែរក្សាប្រព័ន្ធដឹកជញ្ជូនតាមផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ(ផ្លូវ ស្ពាន ចំណតរថយន្ត។ល។)<br>-ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិសម្រាប់អ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីដំណើរការប្រព័ន្ធដឹកជញ្ជូនផ្លូវគោក<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់ការសាងសង់ ជួសជុល ថែទាំ ឬ កែលម្អប្រព័ន្ធដឹកជញ្ជូនតាមផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ<br>+រួមបញ្ចូលទាំង÷ ផ្លូវល្បឿនលឿន ផ្លូវសម្រាប់កង់ និងផ្លូវសម្រាប់ថ្មើរជើង។ល។<br>+មិនរួមបញ្ចូល÷ ការត្រួតពិនិត្យចរាចរណ៍ផ្លូវគោក ដែលបានកំណត់នៅក្នុង ៧០៣១០ ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់ឧស្សាហកម្មផលិតយានយន្ត ដែលបានកំណត់នៅក្នុង ៧០៤៤២ ការសម្អាតផ្លូវ ដែលបានកំណត់នៅក្នុង ៧០៥១០ ការសាងសង់របាំងការពារសំឡេង និងផ្សែងពុល ដែលបានកំណត់នៅក្នុង៧០៥៣០ ការបំពាក់ភ្លើងតាមដងផ្លូវ ដែលបានកំណត់នៅក្នុង ៧០៦៤០។ |
| | | ៧០៤៥២ | ការដឹកជញ្ជូនតាមផ្លូវទឹក | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការប្រើប្រាស់ និងការការពារប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក តាមឆ្នេរ តាមសមុទ្រ និងតាមទន្លេ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (កំពង់ផែ ព្រែក ស្ពាន ទំនប់បាំងរលក។ល។) |

| | | | | |
|---|---|---|---|---|
| | | | | -ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិសម្រាប់អ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេសស្តីពីដំណើរការប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក និងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់ការសាងសង់ ការថែទាំ ឬ កែលម្អប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ<br>+រួមបញ្ចូលទាំង÷ ឧបករណ៍ជំនួយស្វែងរកទិសតាមវិទ្យុទាក់ទង និងផ្កាយរណប ការសង្គ្រោះបន្ទាន់តាមផ្លូវទឹក និងសេវាសណ្តោង<br>+មិនរួមបញ្ចូល÷ ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ទៅអ្នកសាងសង់នាវា ដែលបានកំណត់នៅក្នុង ៧០៤៤២។ |
| | | ៧០៤៥៣ | ការដឹកជញ្ជូនតាមផ្លូវដែក | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការប្រើប្រាស់ ឬ ការថែទាំប្រព័ន្ធដឹកជញ្ជូនផ្លូវដែក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ(គ្រឹះផ្លូវដែក ស្ថានីយអយស្ម័យយាន រួងផ្លូវ។ល។)<br>-ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិសម្រាប់អ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវដែក<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេសស្តីពីដំណើរការប្រព័ន្ធដឹកជញ្ជូនផ្លូវដែកលើសកម្មភាពសាងសង់ផ្លូវដែក<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់ការសាងសង់ ការថែទាំ ឬ កែលម្អប្រព័ន្ធដឹកជញ្ជូនផ្លូវដែក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ<br>+រួមបញ្ចូលទាំង÷ ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកខ្សែវែង និងឆ្លងកាត់ពីទីក្រុងមួយទៅទីក្រុងមួយទៀត ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកនៅទីក្រុង ការលក់ និងការថែទាំក្បាលរថភ្លើង<br>+មិនរួមបញ្ចូល÷ ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ទៅអ្នកផលិតក្បាលរថភ្លើង ដែលបានកំណត់នៅក្នុង ៧០៤៤២ ការសាងសង់របាំងការពារសំឡេង និងផ្សែងពុល ដែលបានកំណត់នៅក្នុង ៧០៥៣០។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤៥៤ | ការដឹកជញ្ជូនតាមផ្លូវអាកាស | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវអាកាស (អាកាសយានដ្ឋាន ផ្លូវយន្តហោះរត់ ស្ថានីយអ្នកដំណើរ ឃ្លាំងទុកយន្តហោះ ឧបករណ៍ជំនួយស្វែងរកទិស បរិក្ខារតាមដានខ្យល់។ល។)<br>-ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិសម្រាប់អ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីដំណើរការប្រព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាស និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាស<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់ការសាងសង់ ការថែទាំ ឬ កែលម្អប្រព័ន្ធដឹកជញ្ជូនផ្លូវអាកាស និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ<br>+រួមបញ្ចូលទាំង÷ ឧបករណ៍ជំនួយស្វែងរកទិសតាមវិទ្យុទាក់ទង និងផ្កាយរណប, ការសង្គ្រោះបន្ទាន់ សេវាដឹកជញ្ជូនទំនិញ និងការគ្រប់គ្រងលើការហោះហើររបស់បុគ្គលឯកជនតាមផ្លូវអាកាស<br>+មិនរួមបញ្ចូល÷ ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ទៅឱ្យក្រុមហ៊ុនផលិតយន្តហោះ ដែលបានកំណត់នៅក្នុង ៧០៤៤២។ |
| | | ៧០៤៥៩ | ការដឹកជញ្ជូនផ្សេងៗ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការប្រើប្រាស់ ឬ ការថែទាំប្រព័ន្ធដឹកជញ្ជូនផ្សេងៗ (រថភ្លើងខ្សែកាប រថយន្តខ្សែកាប កៅអីរ៉ក។ល។)<br>-ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនផ្សេងៗ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីដំណើរការសាងសង់ប្រព័ន្ធដឹកជញ្ជូនផ្សេងៗ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់គាំទ្រដំណើរការ ការសាងសង់ ការថែទាំ ឬ កែលម្អប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធដឹកជញ្ជូនផ្សេងៗ |
| | ៧០៤៦ | | ទំនាក់ទំនង | |

| | | | | |
|---|---|---|---|---|
| | | ៧០៤៦០ | ទំនាក់ទំនង | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ការពង្រីក ការធ្វើឱ្យប្រសើរឡើង ដំណើរការ និងការថែទាំប្រព័ន្ធទំនាក់ទំនង (ប្រៃសណីយ៍ ទូរស័ព្ទ តេឡេក្រាម ប្រព័ន្ធទំនាក់ទំនងឥតខ្សែ និងផ្កាយរណប)<br>-ការរៀបចំឯកសារគតិយុត្ត នៃដំណើរការប្រព័ន្ធទំនាក់ទំនង (ការផ្តល់សិទ្ធិផ្សាយបន្ត ការផ្តល់ប្រេកង់។ល។)<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេសស្ថិតិ ស្តីពីកិច្ចការ និងសេវាទំនាក់ទំនង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់គាំទ្រ ដំណើរការ ការសាងសង់ ការថែទាំ ឬ កែលម្អនូវប្រព័ន្ធទំនាក់ទំនង<br>+មិនរួមបញ្ចូល÷ ឧបករណ៍ជំនួយស្វែងរកទិសតាមវិទ្យុទាក់ទង និងផ្កាយរណប សម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវអាកាស ដែលបានកំណត់នៅក្នុង ៧០៤៥២, ៧០៤៥៤ និងប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលបានកំណត់នៅក្នុង ៧០៨៣០។ |
| | ៧០៤៧ | | ឧស្សាហកម្មផ្សេងៗ | |
| | | ៧០៤៧១ | ការចែកចាយ និងរក្សាទុក | -ការគ្រប់គ្រង ការត្រួតពិនិត្យ ការរៀបចំបទប្បញ្ញត្តិ និងសេវាពាក់ព័ន្ធនឹងការចែកចាយ និងរក្សាទុក (ការផ្តល់អាជ្ញាប័ណ្ណ ការបិទស្លាកអាហារកញ្ចប់ និងទំនិញដទៃសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ការពិនិត្យកម្រិតជញ្ជីង និងម៉ាស៊ីនថ្លឹងផ្សេងៗ។ល។)<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីការចែកចាយ និងការរក្សាទុក<br>- ការគ្រប់គ្រងការត្រួតពិនិត្យតម្លៃ និងគម្រោងកម្រិតតម្លៃ តាមរយៈអ្នកលក់រាយ ឬ លក់ដុំ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់គាំទ្រសកម្មភាពចែកចាយ និងការរក្សាទុក<br>+មិនរួមបញ្ចូល÷ ការបែងចែក ការរក្សាទុក ស្បៀងអាហារ និងសម្ភារប្រើប្រាស់ចាំបាច់សម្រាប់បម្រើឱ្យសកម្មភាពគាំពារពីសង្គម ដែលបានកំណត់នៅក្នុង ៧១០។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤៧២ | សណ្ឋាគារ និងភោជនីយដ្ឋាន | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការសាងសង់ ការពង្រីក ការធ្វើឱ្យប្រសើរឡើង ដំណើរការ ការថែទាំ ការត្រួតពិនិត្យ និងការរៀបចំបទប្បញ្ញត្តិសម្រាប់សណ្ឋាគារ និងភោជនីយដ្ឋាន<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្តីពីកិច្ចការ និងសេវាសណ្ឋាគារ និងភោជ-នីយដ្ឋាន<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់គាំទ្រការសាងសង់ ដំណើរការ ការថែទាំ ឬ ការ-កែលម្អសណ្ឋាគារ និងភោជនីយដ្ឋាន។ |
| | | ៧០៤៧៣ | ទេសចរណ៍ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការលើកស្ទួយ ការអភិវឌ្ឍវិស័យទេសចរណ៍ សកម្មភាពដឹកជញ្ជូនដែលពាក់ព័ន្ធនឹងសណ្ឋាគារនិងភោជនីយដ្ឋាន និងឧស្សាហកម្មផ្សេងៗទៀត ដែលទទួលអត្ថប្រយោជន៍ពីការចូលមករបស់ភ្ញៀវទេសចរ<br>-ដំណើរការរបស់ស្នាក់ការផ្តល់ព័ត៌មានទេសចរណ៍ក្នុង និងក្រៅប្រទេស។ល។ ការរៀបចំយុទ្ធនាការផ្សព្វផ្សាយ រួមមាន÷ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍<br>-ការចងក្រង និងបោះពុម្ពផ្សាយស្ថិតិទេសចរណ៍។ |
| | | ៧០៤៧៤ | គម្រោងអភិវឌ្ឍន៍ពហុគោលបំណង | -គម្រោងអភិវឌ្ឍន៍ពហុគោលបំណង រួមមាន÷ ការបង្កើតថាមពល ការទប់ទល់ទឹកជំនន់ ការស្រោចស្រព និងការកម្សាន្ត<br>-ការគ្រប់គ្រងកិច្ចការ និងសេវាពាក់ព័ន្ធនឹងការសាងសង់ ដំណើរការ ការពង្រីក ការកែលម្អ និងការថែទាំគម្រោងអភិវឌ្ឍន៍ពហុគោលបំណង<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីគម្រោងអភិវឌ្ឍន៍ពហុ-គោលបំណង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន សម្រាប់គាំទ្រការសាងសង់<br>ដំណើរការ ការថែទាំ ឬ ការកែលម្អ គម្រោងអភិវឌ្ឍន៍ពហុគោលបំណង<br>+មិនរួមបញ្ចូល÷ គម្រោងដែលមានមុខងារតែមួយ។ |
| | ៧០៤៨ | | ការស្រាវជ្រាវ និងអភិវឌ្ឍន៍សេដ្ឋកិច្ច | |

| | | | | |
|---|---|---|---|---|
| | | ៧០៤៨១ | ការស្រាវជ្រាវ និងអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និងការងារ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និងការងារ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និងការងារ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌាសាកល-វិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | | ៧០៤៨២ | ការស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌាសាកល-វិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | | ៧០៤៨៣ | ការស្រាវជ្រាវ និងអភិវឌ្ឍឥន្ធនៈ និងថាមពល | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍឥន្ធនៈ និងថាមពល<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍឥន្ធនៈ និងថាមពល ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌាសាកលវិទ្យា-ល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | | ៧០៤៨៤ | ការស្រាវជ្រាវ និងអភិវឌ្ឍអាជីវកម្មរ៉ែក្រៅពីឥន្ធនៈ ការផលិត និងសំណង់ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍអាជីវកម្មរ៉ែក្រៅពីឥន្ធនៈ ការផលិត និងសំណង់<br>-ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍអាជីវកម្មរ៉ែក្រៅពីឥន្ធនៈ ការផលិត និងសំណង់ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និង បណ្ឌាសាកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤៨៥ | ការស្រាវជ្រាវ និងអភិវឌ្ឍការដឹកជញ្ជូន | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍការដឹកជញ្ជូន<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍការដឹកជញ្ជូន ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌិតសភាសកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | | ៧០៤៨៦ | ការស្រាវជ្រាវ និងអភិវឌ្ឍទំនាក់ទំនង | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍទំនាក់ទំនង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍទំនាក់ទំនង ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌិតសភាសកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | | ៧០៤៨៧ | ការស្រាវជ្រាវ និងអភិវឌ្ឍឧស្សាហកម្មផ្សេងៗ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍឧស្សាហកម្មផ្សេងៗ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍឧស្សាហកម្មផ្សេងៗ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌិតសភាសកលវិទ្យា-ល័យនានា<br>+រួមបញ្ចូលទាំង÷ ការស្រាវជ្រាវពាក់ព័ន្ធនឹងការចែកចាយ និងរក្សាទុក សណ្ឋាគារ និងភោជនីយដ្ឋាន ទេសចរណ៍ និងគម្រោងអភិវឌ្ឍន៍ពហុគោលបំណង<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០៤៩ | | សេដ្ឋកិច្ចផ្សេងៗ | |
| | | ៧០៤៩០ | សេដ្ឋកិច្ចផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការងារសេដ្ឋកិច្ចដែលមិនបានកំណត់ក្នុង ៧០៤១, ៧០៤២, ៧០៤៣, ៧០៤៤, ៧០៤៥, ៧០៤៦, ៧០៤៧ ឬ ៧០៤៨។ |
| ៧០៥ | | | ការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះ | |
| | ៧០៥១ | | ការគ្រប់គ្រងសំណល់រឹង | |

| | | | | |
|---|---|---|---|---|
| | | ៧០៥១០ | ការគ្រប់គ្រងសំណល់រឹង | -ការគ្រប់គ្រង ការសាងសង់ ដំណើរការ ការត្រួតពិនិត្យ ការធ្វើអធិការកិច្ច ឬ ការគាំទ្រ ដំណើរការ ការប្រមូលសំណល់ ការកែច្នៃ ការបំលែងទៅជាសារធាតុពុំមានគ្រោះថ្នាក់ និងការបោះចោលសំណល់រឹង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រដំណើរការ ការសាងសង់ ការថែទាំ ឬ ការធ្វើឱ្យប្រព័ន្ធនេះកាន់តែប្រសើរឡើង<br>+រួមបញ្ចូលទាំង÷ ការប្រមូល ប្រព្រឹត្តកម្ម និងបោះចោលសំណល់វិទ្យុសកម្ម។ |
| | ៧០៥២ | | ការគ្រប់គ្រងសំណល់រាវ | |
| | | ៧០៥២០ | ការគ្រប់គ្រងសំណល់រាវ | -ការគ្រប់គ្រង ការសាងសង់ ដំណើរការ ការត្រួតពិនិត្យ ការធ្វើអធិការកិច្ច ឬ ការគាំទ្រទៅលើប្រព័ន្ធលូទឹកស្អុយ និងប្រព័ន្ធបំលែងទឹកកខ្វក់ទៅជាទឹកពុំមានជាតិពុល<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រដំណើរការ ការសាងសង់ ការថែទាំ ឬ ការធ្វើឱ្យប្រព័ន្ធនេះកាន់តែប្រសើរឡើង។ |
| | ៧០៥៣ | | ការគ្រប់គ្រងការបំពុលខ្យល់ និងសំឡេង | |
| | | ៧០៥៣០ | ការគ្រប់គ្រងការបំពុលខ្យល់ និងសំឡេង | -ការគ្រប់គ្រង ការត្រួតពិនិត្យ ការពិនិត្យតាមដាន ដំណើរការ ឬ ការគាំទ្រសកម្មភាពពាក់ព័ន្ធនឹងការកាត់បន្ថយ និងការការពារការបំពុលខ្យល់ និងសំឡេង<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រសកម្មភាព ពាក់ព័ន្ធនឹងការកាត់បន្ថយ និងការការពារការបំពុលខ្យល់ និងសំឡេង។ |
| | ៧០៥៤ | | ការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ | |
| | | ៧០៥៤០ | ការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ | -ការគ្រប់គ្រង ការសាងសង់ ដំណើរការ ការត្រួតពិនិត្យ ការធ្វើអធិការកិច្ច ឬ ការគាំទ្រសកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ។ |
| | ៧០៥៥ | | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះ | |

| | | | | |
|---|---|---|---|---|
| | | ៧០៥៥០ | ការស្រាវជ្រាវ និងអភិវឌ្ឍការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះ | -ការគ្រប់គ្រង និងដំណើរការពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍការគ្រប់គ្រងគុណភាព បរិស្ថាន និង អភិរក្សជីវចម្រុះ<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍការគ្រប់គ្រងគុណភាព បរិស្ថាន និងអភិរក្សជីវចម្រុះ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ដាសាកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០៥៦ | | ការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះផ្សេងៗ | |
| | | ៧០៥៦០ | ការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការងារលើកកម្ពស់ការគ្រប់គ្រងគុណភាពបរិស្ថាន និង អភិរក្សជីវចម្រុះ ដូចជាការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការសម្របសម្រួល និងការត្រួតពិនិត្យ ដំណើរការ គោលនយោបាយ ផែនការ កម្មវិធី ឬ ថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះផ្សេងៗ<br>+រួមបញ្ចូលទាំង÷ សេវា និងការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះ ដែលមិនអាចកំណត់នៅក្នុង ៧០៥១, ៧០៥២, ៧០៥៣, ៧០៥៤ ឬ ៧០៥៥។ |
| ៧០៦ | | | ការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ | |
| | ៧០៦១ | | ការរៀបចំលំនៅដ្ឋាន | |
| | | ៧០៦១០ | ការរៀបចំលំនៅដ្ឋាន | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការលើកស្ទួយ ការតាមដាន ការវាយតម្លៃ ការអភិវឌ្ឍន៍ ការដោះស្រាយផលប៉ះពាល់ ឬ ការរៀបចំបទប្បញ្ញត្តិនៃការរៀបចំលំនៅដ្ឋាន<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស ស្ដីពីការរៀបចំលំនៅដ្ឋាន<br>-ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការពង្រីក ការធ្វើឱ្យកាន់តែប្រសើរឡើង ឬ ការ-ថែទាំគម្រោងលំនៅដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ ការកែលម្អ និងការរៀបចំបទប្បញ្ញត្តិនៃបទដ្ឋានសាងសង់ ដែលបានកំណត់នៅក្នុង ៧០៤៤៣ ឬ អត្ថប្រយោជន៍ជាសាច់ប្រាក់ និងជាសម្ភារ ដើម្បីជួយដល់ក្រុមគ្រួសារសម្រាប់ថ្លៃសាងសង់លំនៅដ្ឋាន ដែលបានកំណត់នៅក្នុង ៧១០៦០។ |
| | ៧០៦២ | | ការគ្រប់គ្រងសហគមន៍ | |
| | | ៧០៦២០ | ការគ្រប់គ្រងសហគមន៍ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំផែនការ ការកែលម្អ ការអភិវឌ្ឍន៍ ការរៀបចំបទប្បញ្ញត្តិ ការកំណត់តំបន់ដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដូចជា÷ ការសង់លំនៅដ្ឋាន ការរៀបចំតំបន់ឧស្សាហកម្ម បណ្ដាញអគ្គិសនី និងទឹកស្អាត សេវាសុខភាព សេវាអប់រំ ការកម្សាន្ត។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្ដីពីកិច្ចការ និងសេវាគ្រប់គ្រងសហគមន៍<br>+មិនរួមបញ្ចូល÷ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធលើដីកសិកម្ម ដែលបានកំណត់នៅក្នុង ៧០៤២១, សំណង់ទូទៅ ដែលបានកំណត់នៅក្នុង ៧០៤៤៣ ឬការសាងសង់លំនៅដ្ឋាន ដែលបានកំណត់នៅក្នុង ៧០៦១០។ |
| | ៧០៦៣ | | ការផ្គត់ផ្គង់ទឹក | |
| | | ៧០៦៣០ | ការផ្គត់ផ្គង់ទឹក | -ការគ្រប់គ្រង ការសិក្សាពីតម្រូវការនាពេលអនាគត ការធ្វើអាទិភាវូបនីយកម្ម ការសាងសង់ ដំណើរការ ការត្រួតពិនិត្យ និងការរៀបចំបទប្បញ្ញត្តិនៃការផ្គត់ផ្គង់ទឹកស្អាត រួមទាំងការត្រួតពិនិត្យគុណភាព និងតម្លៃ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្ដីពីកិច្ចការ និងសេវាផ្គត់ផ្គង់ទឹក<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រដំណើរការ ការសាងសង់ ការថែទាំ ឬ ការធ្វើឱ្យប្រព័ន្ធផ្គត់ផ្គង់ទឹកកាន់តែប្រសើរឡើង<br>+មិនរួមបញ្ចូល÷ ប្រព័ន្ធស្រោចស្រព ដែលបានកំណត់នៅក្នុង ៧០៤២១ គម្រោងពហុគោលបំណង ដែលបានកំណត់នៅក្នុង ៧០៤៧៤, ការគ្រប់គ្រង និងការបំលែងទឹកកខ្វក់ទៅជាទឹកពុំមានជាតិពុល ដែលបានកំណត់នៅក្នុង ៧០៥២០។ |
| | ៧០៦៤ | | ការបំពាក់ភ្លើងតាមដងផ្លូវសាធារណៈ | |

| | | | | |
|---|---|---|---|---|
| | | ៧០៦៤០ | ការបំពាក់ភ្លើងតាមដងផ្លូវសាធារណៈ | -ការគ្រប់គ្រង ការបំពាក់ ដំណើរការ ការថែទាំ ការកែលម្អ ការរៀបចំបទប្បញ្ញត្តិស្តង់ដារពាក់ព័ន្ធនឹងការបំពាក់ភ្លើងតាមដងផ្លូវសាធារណៈ។ល។<br>+មិនរួមបញ្ចូល÷ កិច្ចការ និងសេវាការបំពាក់ភ្លើងក្នុងការសាងសង់ និងប្រតិបត្តិការលើផ្លូវល្បឿនលឿន ដែលបានកំណត់នៅក្នុង ៧០៤៥១។ |
| | ៧០៦៥ | | ការស្រាវជ្រាវ និងអភិវឌ្ឍការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ | |
| | | ៧០៦៥០ | ការស្រាវជ្រាវ និងអភិវឌ្ឍការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌាសាកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០,ការស្រាវជ្រាវ និងអភិវឌ្ឍនៃការសាងសង់ទូទៅ ដែលបានកំណត់នៅក្នុង ៧០៤៨៤។ |
| | ៧០៦៦ | | ការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ផ្សេងៗ | |
| | | ៧០៦៦០ | ការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ផ្សេងៗ ដូចជាការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការសម្របសម្រួល និងការត្រួតពិនិត្យ ដំណើរការ គោលនយោបាយ ផែនការ កម្មវិធី ឬ ថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ផ្សេងៗ<br>+រួមបញ្ចូលទាំង÷ ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រសកម្មភាពដែលពាក់ព័ន្ធនឹងការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍ផ្សេងៗ ដែលមិនអាចកំណត់នៅក្នុង ៧០៦១, ៧០៦២, ៧០៦៣, ៧០៦៤ ឬ ៧០៦៥។ |
| ៧០៧ | | | សុខាភិបាល | |

| | | | | |
|---|---|---|---|---|
| | ៧០៧១ | | ឱសថ សម្ភារ និងបរិក្ខារពេទ្យ | ឱសថ សម្ភារ និងបរិក្ខារពេទ្យសម្រាប់បុគ្គល ឬ ក្រុមគ្រួសារដែលសម្រាក ឬ មិនសម្រាកនៅមន្ទីរពេទ្យ ដែលផ្តល់ដោយឱសថការី ឬ អ្នកផ្គត់ផ្គង់សម្ភារបរិក្ខារពេទ្យ ទោះបីជាមាន ឬ គ្មានវេជ្ជបញ្ជា។ សេវាប្រហាក់ប្រហែលនេះដូចជា សេវាកម្មពិគ្រោះជំងឺ ដែលបានកំណត់នៅក្នុង ៧០៧២, សេវាសម្រាកនៅមន្ទីរពេទ្យ ដែលបានកំណត់នៅក្នុង ៧០៧៣។ |
| | | ៧០៧១១ | ឱសថ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្រការផ្តល់ឱសថ រួមមាន÷ ឱសថគ្រប់ប្រភេទ សេរ៉ូម ថ្នាំបង្ការ វីតាមីន សារធាតុរ៉ែ ខ្លាញ់ថ្លើមត្រី ឬ ថ្នាំពន្យារកំណើត។ល។ |
| | | ៧០៧១២ | សម្ភារពេទ្យ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្រការផ្តល់សម្ភារពេទ្យ រួមមាន÷ ប្រដាប់វាស់កម្តៅក្នុងវេជ្ជសាស្ត្រ បង់ស្អិត ស៊ីរ៉ាំង ឧបករណ៍សង្គ្រោះបឋម ដបទឹកក្តៅ ថង់ខ្ចប់ទឹកកក ឧបករណ៍តេស្តពិនិត្យផ្ទៃពោះ។ល។ |
| | | ៧០៧១៣ | បរិក្ខារពេទ្យ | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រការផ្តល់បរិក្ខារពេទ្យ រួមមាន÷ វ៉ែនតាព្យាបាល ឧបករណ៍ជំនួយការស្តាប់ អវយវៈសិប្បនិម្មិត ឧបករណ៍សិប្បនិម្មិតដទៃទៀត ឃ្នាបអបនិងទ្រឆ្អឹង ស្បែកជើងអបឆ្អឹង ខ្សែចងចង្កេះ ទម្រឃ្នាបអបក សម្ភារម៉ាស្សាវេជ្ជសាស្ត្រ គ្រែ ឈើច្រត់ និងឧបករណ៍អេឡិចត្រូនិកដទៃទៀតសម្រាប់តាមដានសម្ពាធឈាម។ល។<br>+រួមបញ្ចូលទាំង÷ ពុម្ពធ្មេញ តែមិនមែនតម្លៃដាក់ធ្មេញនោះទេ, ការជួសជុលបរិក្ខារពេទ្យ<br>+មិនរួមបញ្ចូល÷ ការជួលឧបករណ៍ព្យាបាល ដែលបានកំណត់នៅក្នុង ៧០៧២៤។ |
| | ៧០៧២ | | សេវាកម្មពិគ្រោះជំងឺ | សេវាកម្មពិគ្រោះជំងឺ រួមមាន សេវាពិគ្រោះវេជ្ជសាស្ត្រទូទៅ, សេវាវេជ្ជសាស្ត្រឯកទេស, សេវាពិគ្រោះទន្តសាស្ត្រ, សេវាពិគ្រោះវេជ្ជសាស្ត្របន្ទាប់បន្សំ សម្រាប់បុគ្គល ឬ ក្រុមគ្រួសារដែលមិនសម្រាកនៅមន្ទីរពេទ្យ។ សេវាសម្រាកនៅមន្ទីរពេទ្យទូទៅ, សេវាសម្រាកនៅមន្ទីរពេទ្យឯកទេស, សេវាសម្រាកនៅមជ្ឈមណ្ឌលគាំពារមាតា និងទារក, សេវាថែទាំ និងការសម្រាកព្យាបាលនៅផ្ទះ ដែលបានកំណត់នៅក្នុង ៧០៧៣។ |

| | | | | |
|---|---|---|---|---|
| | | ៧០៧២១ | សេវាពិគ្រោះវេជ្ជសាស្ត្រទូទៅ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬការគាំទ្រសេវាវេជ្ជសាស្ត្រទូទៅ មិនសម្រាកនៅមន្ទីរពេទ្យ ដែលផ្តល់ដោយ មន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិកដែលមានស្តង់ដារត្រឹមត្រូវ<br>+មិនរួមបញ្ចូល÷ សេវាមន្ទីរពិសោធន៍វិភាគវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលថតកាំរស្មីអ៊ិច ដែលបានកំណត់នៅក្នុង ៧០៧២៤។ |
| | | ៧០៧២២ | សេវាវេជ្ជសាស្ត្រឯកទេស | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬ ការគាំទ្រសេវាវេជ្ជសាស្ត្រឯកទេស មិនសម្រាកនៅមន្ទីរពេទ្យដែលផ្តល់ដោយ មន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក ដែលមានស្តង់ដារត្រឹមត្រូវ<br>+រួមបញ្ចូលទាំង÷ សេវាគ្រូពេទ្យឯកទេសតម្រង់ធ្មេញ។<br>+មិនរួមបញ្ចូល÷ គ្លីនិកទន្តសាស្ត្រ និងទន្តបណ្ឌិត ដែលបានកំណត់នៅក្នុង ៧០៧២៣ សេវាមន្ទីរពិសោធន៍វិភាគវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលថតកាំរស្មីអ៊ិច ដែលបានកំណត់នៅក្នុង ៧០៧២៤។ |
| | | ៧០៧២៣ | សេវាពិគ្រោះទន្តសាស្ត្រ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬ ការគាំទ្រសេវាទន្តសាស្ត្រ មិនសម្រាកនៅមន្ទីរពេទ្យដែលផ្តល់ដោយ មន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក ដែលមានស្តង់ដារត្រឹមត្រូវ<br>+រួមបញ្ចូលទាំង÷ សេវាដាក់ធ្មេញសិប្បនិម្មិត<br>+មិនរួមបញ្ចូល÷ ថ្លៃធ្មេញសិប្បនិម្មិត ដែលបានកំណត់នៅក្នុង ៧០៧១៣, សេវាគ្រូពេទ្យជំនាញតម្រង់ធ្មេញ ដែលបានកំណត់នៅក្នុង ៧០៧២២, សេវាមន្ទីរពិសោធន៍វិភាគវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលថតកាំរស្មីអ៊ិច ដែលបានកំណត់នៅក្នុង ៧០៧២៤។ |
| | | ៧០៧២៤ | សេវាពិគ្រោះវេជ្ជសាស្ត្របន្ទាប់បន្សំ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬការគាំទ្រសេវាវេជ្ជសាស្ត្របន្ទាប់បន្សំ មិនសម្រាកនៅមន្ទីរពេទ្យដែលផ្តល់ដោយ មន្ទីរពេទ្យ មណ្ឌលសុខភាព ឬគ្លីនិក ដែលព្យាបាលដោយគិលានុបដ្ឋាក គិលានុបដ្ឋាកយិកា គ្រូពេទ្យព្យាបាលដោយចលនា។ល។<br>+រួមបញ្ចូលទាំង÷ គ្រូពេទ្យចាក់ម្ជុលវិទ្យាសាស្ត្រ គ្រូពេទ្យព្យាបាលគ្រេចថ្លោះ អ្នកឯកទេសចក្ខុ គ្រូថ្នាំបុរាណ។ល។ សេវាមន្ទីរពិសោធន៍វិភាគវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលថតកាំរស្មីអ៊ិច ការជួលសម្ភារបរិក្ខារពេទ្យសម្រាប់ការព្យាបាលដោយចលនា ការព្យាបាលដោយប្រើឧបករណ៍ហាត់ប្រាណណែនាំដោយគ្រូពេទ្យ សេវារថយន្តសង្គ្រោះបន្ទាន់ផ្សេងៗក្រៅពីសេវាសង្គ្រោះបន្ទាន់របស់មន្ទីរពេទ្យ។<br>+មិនរួមបញ្ចូល÷ មន្ទីរពិសោធន៍សេវាសុខភាពសាធារណៈ ដែលបានកំណត់នៅក្នុង ៧០៧៤០, មន្ទីរពិសោធន៍បម្រើឱ្យការស្រាវជ្រាវផ្នែកសុខាភិបាល ដែលបានកំណត់នៅក្នុង ៧០៧៥០។ |

| | | | | |
|---|---|---|---|---|
| | ៧០៧៣ | | សេវាមន្ទីរពេទ្យ | សេវាមន្ទីរពេទ្យ រួមមាន÷ សេវាសម្រាកនៅមន្ទីរពេទ្យទូទៅ, សេវាសម្រាកនៅមន្ទីរពេទ្យឯកទេស, សេវាសម្រាកនៅមជ្ឈមណ្ឌលគាំពារមាតា និងទារក, សេវាថែទាំ និងការសម្រាកព្យាបាលនៅផ្ទះ<br>+រួមបញ្ចូលទាំង÷ ឱសថ អវយវៈសិប្បនិម្មិត ឧបករណ៍ពេទ្យ ការចំណាយផ្សេងទៀត ដូចជា÷ រដ្ឋបាលមិនមែនសម្ភារពេទ្យ អាហារ ភេសជ្ជៈ ការស្នាក់នៅរបស់បុគ្គលិកមន្ទីរពេទ្យ។ល។<br>+មិនរួមបញ្ចូល÷ មន្ទីរពេទ្យយោធាភូមិភាគ ឬ មូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០២១, កន្លែងវះកាត់ គ្លីនិក ដែលមិនទទួលសម្រាក ដែលបានកំណត់នៅក្នុង ៧០៧២, សេវាថែទាំសុខភាពរយៈពេលវែងនៅវិទ្យាស្ថានសម្រាប់ជនពិការ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ដែលបានកំណត់នៅក្នុង ៧១០១២, សេវាថែទាំសុខភាពរយៈពេលវែងនៅមជ្ឈមណ្ឌលចាស់ជរា ដែលបានកំណត់នៅក្នុង ៧១០២០, អ្នកស្នាក់នៅមន្ទីរពេទ្យដែលទទួលបានការគាំទ្រពីគម្រោងការការពារពីសង្គមសម្រាប់អ្នកជម្ងឺ ឬ របួសជាបណ្តោះអាសន្ន ដែលបានកំណត់នៅក្នុង ៧១០១១។ |
| | | ៧០៧៣១ | សេវាសម្រាកនៅមន្ទីរពេទ្យទូទៅ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬការគាំទ្រសេវាវេជ្ជសាស្ត្រទូទៅ សម្រាកនៅមន្ទីរពេទ្យដែលផ្តល់ដោយ មន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក ដែលមានស្តង់ដារត្រឹមត្រូវ<br>+មិនរួមបញ្ចូល÷ សេវាមជ្ឈមណ្ឌលគាំពារមាតា និងទារក ដែលបានកំណត់នៅក្នុង ៧០៧៣៣។ |
| | | ៧០៧៣២ | សេវាសម្រាកនៅមន្ទីរពេទ្យឯកទេស | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬ ការគាំទ្រសេវាសម្រាកនៅមន្ទីរពេទ្យ វេជ្ជសាស្ត្រឯកទេសដែលផ្តល់ដោយមន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក ដែលមានស្តង់ដារត្រឹមត្រូវ ដូចជា÷ ជំងឺសន្ទះទ្រូងរបេង ហង់សិន មហារីក ជំងឺត្រចៀក ច្រមុះ និងបំពង់ក ជំងឺវិកលចរិត ជំងឺកុមារ និងជំងឺផ្សេងៗជាច្រើនទៀត<br>+មិនរួមបញ្ចូល÷ សេវាមជ្ឈមណ្ឌលគាំពារមាតា និងទារក ដែលបានកំណត់នៅក្នុង ៧០៧៣៣។ |
| | | ៧០៧៣៣ | សេវាសម្រាកនៅមជ្ឈមណ្ឌលគាំពារមាតា និងទារក | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬការគាំទ្រសេវាសម្រាកនៅមន្ទីរពេទ្យនៃមជ្ឈមណ្ឌលគាំពារមាតា និងទារក រួមទាំងសម្ភពដែលផ្តល់ដោយមន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក |
| | | ៧០៧៣៤ | សេវាថែទាំ និងការសម្រាកព្យាបាលនៅផ្ទះ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬ ការគាំទ្រសេវាថែទាំ និងការសម្រាកព្យាបាលនៅផ្ទះ បន្ទាប់ពីទទួលការវះកាត់ ឬ ស្ថានភាពជំងឺធូរស្រាល ប៉ុន្តែទាមទារព្យាបាលបន្តនៅផ្ទះដែលផ្តល់ដោយមន្ទីរពេទ្យ មណ្ឌលសុខភាព ឬ គ្លីនិក<br>+រួមបញ្ចូលទាំង÷ សេវាព្យាបាលសុខភាពចាស់ជរានៅមជ្ឈមណ្ឌលថែទាំចាស់ជរា ការព្យាបាលរយៈពេលខ្លីនៅមជ្ឈមណ្ឌលស្តារនីតិសម្បទា។ |

| | | | | |
|---|---|---|---|---|
| | ៧០៧៤ | | សេវាសុខភាពសាធារណៈ | |
| | | ៧០៧៤០ | សេវាសុខភាពសាធារណៈ | -ការគ្រប់គ្រង ការពិនិត្យតាមដាន ដំណើរការ ឬការគាំទ្រសេវាសុខភាពសាធារណៈដូចជាប្រតិបត្តិការស្តុកទុកឈាម (ការប្រមូល រក្សាទុក ចែកចាយ) មន្ទីរពិសោធន៍វិភាគរកជំងឺ, ការបង្ការជំងឺផ្សេងៗ, ការត្រួតពិនិត្យតាមដានអាហារូបត្ថម្ភ និងសុខភាពទារក និងកុមារ, ការប្រមូលទិន្នន័យជំងឺឆ្លង សេវារៀបចំផែនការគ្រួសារ និងសេវាផ្សេងៗទៀត<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅអំពីបញ្ហាសុខភាពសាធារណៈ<br>+រួមបញ្ចូលទាំង÷ សេវាសុខភាពសាធារណៈដែលផ្តល់ដោយក្រុមការងារពិសេស ទៅកាន់ក្រុមអ្នកជំងឺដែលភាគច្រើនស្ថិតនៅស្ថានភាពសុខភាពល្អ កន្លែងការងារ សាលារៀន។ល។ ដែលសេវាទាំងនេះមិនមែនជាសេវារបស់មន្ទីរពេទ្យ ឬ គ្លីនិកណាមួយ និងមិនតម្រូវឱ្យផ្តល់ដោយវេជ្ជបណ្ឌិតឡើយ<br>+មិនរួមបញ្ចូល÷ សេវាពិគ្រោះវេជ្ជសាស្ត្របន្ទាប់បន្សំ ដែលបានកំណត់នៅក្នុង ៧០៧២៤, មន្ទីរពិសោធន៍បម្រើឱ្យការស្រាវជ្រាវផ្នែកសុខាភិបាល ដែលបានកំណត់នៅក្នុង ៧០៧៥០។ |
| | ៧០៧៥ | | ការស្រាវជ្រាវ និងអភិវឌ្ឍសុខាភិបាល | |
| | | ៧០៧៥០ | ការស្រាវជ្រាវ និងអភិវឌ្ឍសុខាភិបាល | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍសុខាភិបាល<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធនដើម្បីគាំទ្រដល់ការស្រាវជ្រាវសុខាភិបាល ដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជា វិទ្យាស្ថានស្រាវជ្រាវ និងសាកលវិទ្យាល័យ<br>+រួមបញ្ចូលទាំង÷ មន្ទីរពិសោធន៍ដែលចូលរួមក្នុងការកំណត់មូលហេតុជំងឺ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០៧៦ | | សុខាភិបាលផ្សេងៗ | |
| | | ៧០៧៦០ | សុខាភិបាលផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំវិស័យសុខាភិបាល ដូចជាការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការសម្របសម្រួល ការត្រួតពិនិត្យ ដំណើរការ គោលនយោបាយ ផែនការ កម្មវិធី ឬថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីសុខាភិបាល |

| | | | | |
|---|---|---|---|---|
| | | | | +រួមបញ្ចូលទាំង÷ សេវា និងការងារពាក់ព័ន្ធសុខាភិបាល ដែលមិនអាចកំណត់នៅក្នុង ៧០៧១, ៧០៧២, ៧០៧៣, ៧០៧៤ ឬ ៧០៧៥។ |
| ៧០៨ | | | ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា | |
| | ៧០៨១ | | ការកម្សាន្ត និងកីឡា | |
| | | ៧០៨១០ | ការកម្សាន្ត និងកីឡា | -ការគ្រប់គ្រង ការផ្តល់សេវាកម្មកម្សាន្ត និងកីឡា ពាក់ព័ន្ធនឹងដំណើរការ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យ ឬ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកម្សាន្ត និងកីឡា ដូចជា÷ ទីលានកម្សាន្ត តារាងវាយ តេនីស ទីលានវាយកូនបាល់ ផ្លូវរត់ ទីលានវាយកូនហ្គោល សង្វៀនប្រដាល់ កន្លែងហាត់កាយសម្ព័ន្ធ សួនសាធារណៈ ឧទ្យាន ឆ្នេរសមុទ្រ កន្លែងបោះជំរុំ។ល។<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រដល់កីឡាករជាក្រុម ឬ ជាបុគ្គល<br>+រួមបញ្ចូលទាំង÷ ទីកន្លែងស្នាក់នៅសម្រាប់ទស្សនិកជន ថ្នាក់ជាតិ និងថ្នាក់តំបន់នៅក្នុងក្របខណ្ឌព្រឹត្តិការណ៍កីឡា<br>+មិនរួមបញ្ចូល÷ សួនសត្វ និងសួនរុក្ខជាតិ អាងត្រីសម្រាប់កម្សាន្ត និងស្ថាប័នស្រដៀងគ្នា ដែលបានកំណត់នៅក្នុង ៧០៨២០ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាកម្សាន្ត និងកីឡា ដែលមាននៅក្នុងស្ថាប័នអប់រំ ដែលបានកំណត់នៅក្នុង ៧០៩។ |
| | ៧០៨២ | | សិល្បៈ និងវប្បធម៌ | |
| | | ៧០៨២០ | សិល្បៈ និងវប្បធម៌ | -ការគ្រប់គ្រង ការផ្តល់សេវាសិល្បៈ និងវប្បធម៌ ពាក់ព័ន្ធនឹងដំណើរការ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យ ឬ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសិល្បៈ និងវប្បធម៌ ដូចជាបណ្ណាល័យ សារមន្ទីរ សាលមហោស្រព រោងល្ខោន ការប្រគុំតន្ត្រី ផលិតកម្មភាពយន្ត រោងតាំងពិព័រណ៍ សួនសត្វ សួនរុក្ខជាតិ និងអាងត្រីសម្រាប់កម្សាន្ត។ល។<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីគាំទ្រដល់សិល្បករ អ្នកនិពន្ធ អ្នកច្នៃម៉ូត និងកិច្ចការផ្សេងៗដែលគាំទ្រក្នុងវិស័យសិល្បៈ និងវប្បធម៌<br>+រួមបញ្ចូលទាំង÷ កម្មវិធីថ្នាក់ជាតិ ថ្នាក់តំបន់ ដែលរៀបចំឡើងមិនមែនក្នុងគោលបំណងដើម្បីទាក់ទាញភ្ញៀវទេសចរ |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ ព្រឹត្តិការណ៍សិល្បៈ និងវប្បធម៌ដែលរៀបចំនៅក្រៅប្រទេសដើម្បីបង្ហាញអន្តរជាតិ ដែលបានកំណត់នៅក្នុង ៧០១១៣ កម្មវិធីសិល្បៈ និងវប្បធម៌ថ្នាក់ជាតិ ថ្នាក់តំបន់ ដែលរៀបចំឡើងក្នុងគោល-បំណងដើម្បីទាក់ទាញភ្ញៀវទេសចរ ដែលបានកំណត់នៅក្នុង ៧០៤៧៣ ការផ្សព្វផ្សាយសម្ភារសិល្បៈ និងវប្បធម៌ ដែលបានកំណត់នៅក្នុង ៧០៨៣០។ |
| | ៧០៨៣ | | សេវាកម្មផ្សព្វផ្សាយ និងការបោះពុម្ព | |
| | | ៧០៨៣០ | សេវាកម្មផ្សព្វផ្សាយ និងការបោះពុម្ព | -ការគ្រប់គ្រង ការផ្សព្វផ្សាយ និងការបោះពុម្ព ពាក់ព័ន្ធនឹងដំណើរការ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យ ឬ ការគាំទ្រដល់ការផ្សព្វផ្សាយ និងការបោះពុម្ព<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធនដើម្បីគាំទ្រដល់ការសាងសង់ ឬ ការទិញបរិក្ខារសម្រាប់ការផ្សព្វផ្សាយ ដូចជា÷ ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្ដី ឬ សៀវភៅ<br>+មិនរួមបញ្ចូល÷ ការិយាល័យ និងរោងពុម្ពរបស់រដ្ឋាភិបាល ដែលបានកំណត់នៅក្នុង ៧០១៣៣, ការផ្ដល់ការអប់រំតាមរយៈការផ្សព្វផ្សាយទូរទស្សន៍ ដែលបានកំណត់នៅក្នុង ៧០៩។ |
| | ៧០៨៤ | | សាសនា និងសេវាសហគមន៍ផ្សេងៗ | |
| | | ៧០៨៤០ | សាសនា និងសេវាសហគមន៍ផ្សេងៗ | -ការគ្រប់គ្រង សាសនា និងសេវាសហគមន៍ផ្សេងៗ ពាក់ព័ន្ធនឹងការគាំទ្រសម្រាប់ដំណើរការ ការថែរក្សា និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងសាសនា រួមទាំងការឧបត្ថម្ភថវិកាដល់អាចារ្យ និងមន្ត្រីទទួលបន្ទុកកិច្ចការសាសនាផ្សេងទៀត<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រសហគមន៍ សម្រាប់បងប្អូនប្រជាពលរដ្ឋ យុវជន អង្គការសង្គម ឬ សហជីពការងារ និងគណបក្សនយោបាយ |
| | ៧០៨៥ | | ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា | |
| | | ៧០៨៥០ | ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនាដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ វិទ្យាស្ថានស្រាវជ្រាវ និងបណ្ឌាសាកលវិទ្យាល័យនានា |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០ |
| | ៧០៨៦ | | ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនាផ្សេងៗ | |
| | | ៧០៨៦០ | ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនាផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា ដូចជា÷ ការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការសម្របសម្រួល ការពិនិត្យតាមដានដំណើរការ គោលនយោបាយ ផែនការ កម្មវិធី ឬ ថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនាផ្សេងៗ<br>+រួមបញ្ចូលទាំង÷ សេវា និងការងារពាក់ព័ន្ធការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនាផ្សេងៗ ដែលមិនអាចកំណត់នៅក្នុង ៧០៨១, ៧០៨២, ៧០៨៣, ៧០៨៤ ឬ ៧០៨៥។ |
| ៧០៩ | | | ការអប់រំ | |
| | ៧០៩១ | | ការអប់រំកម្រិតមុនបឋម និងបឋមសិក្សា | |
| | | ៧០៩១១ | ការអប់រំកម្រិតមុនបឋមសិក្សា | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលា និងស្ថាប័នអប់រំផ្សេងទៀតដែលផ្តល់ការអប់រំកម្រិតមុនបឋមសិក្សា<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំសម្រាប់ការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | | ៧០៩១២ | ការអប់រំកម្រិតបឋមសិក្សា | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលា និងស្ថាប័នអប់រំផ្សេងទៀតដែលផ្តល់ការអប់រំកម្រិតបឋមសិក្សា<br>+រួមបញ្ចូលទាំង÷ កម្មវិធីអក្ខរកម្មសម្រាប់សិស្សដែលមានអាយុច្រើន ហើយត្រូវសិក្សាកម្រិតបឋមសិក្សា<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំសម្រាប់ការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | ៧០៩២ | | ការអប់រំកម្រិតមធ្យមសិក្សា | |
| | | ៧០៩២១ | ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលារៀន និងស្ថាប័នអប់រំផ្សេងទៀតដែលផ្តល់ការអប់រំមធ្យមសិក្សាបឋមភូមិ |

| | | | | |
|---|---|---|---|---|
| | | | | -អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់កម្មវិធីសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ<br>+រួមបញ្ចូលទាំង÷ ការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សគ្រប់វ័យ ដែលត្រូវសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំលើការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | | ៧០៩២២ | ការអប់រំមធ្យមសិក្សាទុតិយភូមិ | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលារៀន និងស្ថាប័នអប់រំផ្សេងទៀតដែលផ្តល់ការអប់រំមធ្យមសិក្សាទុតិយភូមិ<br>-អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់កម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ<br>+រួមបញ្ចូលទាំង÷ ការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សគ្រប់វ័យ ដែលត្រូវសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំលើការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | ៧០៩៣ | | ការអប់រំកម្រិតបរិញ្ញាប័ត្ររង និងកម្រិតប្រហាក់ប្រហែល | |
| | | ៧០៩៣០ | ការអប់រំកម្រិតបរិញ្ញាប័ត្ររង និងកម្រិតប្រហាក់ប្រហែល | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលារៀន និងស្ថាប័នអប់រំផ្សេងទៀតដែលផ្តល់ការអប់រំកម្រិតបរិញ្ញាប័ត្ររង និងកម្រិតប្រហាក់ប្រហែល<br>-អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់កម្មវិធីសិក្សាកម្រិតបរិញ្ញាប័ត្ររង និងកម្រិតប្រហាក់ប្រហែល<br>+រួមបញ្ចូលទាំង÷ ការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សគ្រប់វ័យ ដែលត្រូវសិក្សានៅកម្រិតបរិញ្ញាប័ត្ររង និងកម្រិតប្រហាក់ប្រហែល<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំលើការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | ៧០៩៤ | | ការអប់រំកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សា | |

| | | | | |
|---|---|---|---|---|
| | | ៧០៩៤១ | ការអប់រំកម្រិតបរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងកម្រិតប្រហាក់ប្រហែល | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬការគាំទ្រសាលារៀន និងស្ថាប័នអប់រំផ្សេងទៀត ដែលផ្តល់ការអប់រំកម្រិតបរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងកម្រិតប្រហាក់ប្រហែល<br>-អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់កម្មវិធីសិក្សានៃការអប់រំកម្រិតបរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងកម្រិតប្រហាក់ប្រហែល<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំលើការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | | ៧០៩៤២ | ការអប់រំកម្រិតបណ្ឌិត និងកម្រិតប្រហាក់ប្រហែល | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលារៀន និងស្ថាប័នអប់រំផ្សេងទៀត ដែលផ្តល់ការអប់រំកម្រិតបណ្ឌិត និងកម្រិតប្រហាក់ប្រហែល<br>-អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់កម្មវិធីសិក្សានៃការអប់រំកម្រិតបណ្ឌិត និងកម្រិតប្រហាក់ប្រហែល<br>+មិនរួមបញ្ចូល÷ សេវាបន្ទាប់បន្សំលើការអប់រំ ដែលបានកំណត់នៅក្នុង ៧០៩៦០។ |
| | ៧០៩៥ | | ការអប់រំមិនកំណត់កម្រិត | |
| | | ៧០៩៥០ | ការអប់រំមិនកំណត់កម្រិត | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬ ការគាំទ្រសាលារៀន និងស្ថាប័ន ដែលផ្តល់ការអប់រំមិនកំណត់កម្រិត ដែលមិនតម្រូវឱ្យមានលក្ខខណ្ឌនៃការអប់រំឡើយ ហើយផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងវប្បធម៌<br>-អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ ដើម្បីគាំទ្រដល់ការអប់រំមិនកំណត់កម្រិត |
| | ៧០៩៦ | | សេវាគាំទ្រផ្សេងៗសម្រាប់ការអប់រំ | |
| | | ៧០៩៦០ | សេវាគាំទ្រផ្សេងៗសម្រាប់ការអប់រំ | -ការគ្រប់គ្រង ការត្រួតពិនិត្យ ដំណើរការ ឬការគាំទ្រសម្រាប់ការអប់រំ រួមមាន÷ ការដឹកជញ្ជូន ចំណីអាហារ កន្លែងស្នាក់នៅ ការថែទាំវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងសេវាបន្ទាប់បន្សំផ្សេងៗទៀត ដើម្បីគាំទ្រដល់ការអប់រំគ្រប់កម្រិត<br>+មិនរួមបញ្ចូល÷ ការត្រួតពិនិត្យ និងសេវាបង្ការសុខភាពនៅតាមសាលារៀន ដែលបានកំណត់នៅក្នុង ៧០៧៤០, អាហារូបករណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ប្រាក់ឧបត្ថម្ភ សម្រាប់សេវាគាំទ្រផ្សេងៗដល់ការអប់រំគ្រប់កម្រិត ដែលបានកំណត់នៅក្នុង ៧០៩១,៧០៩២, ៧០៩៣, ៧០៩៤ ឬ ៧០៩៥។ |

| | | | | |
|---|---|---|---|---|
| | ៧០៩៧ | | ការស្រាវជ្រាវ និងអភិវឌ្ឍការអប់រំ | |
| | | ៧០៩៧០ | ការស្រាវជ្រាវ និងអភិវឌ្ឍការអប់រំ | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍការអប់រំ<br>-ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ ដែលបានអនុវត្ត និងការអភិវឌ្ឍន៍បែបពិសោធន៍ ពាក់ព័ន្ធនឹងការអប់រំដែលផ្តល់ដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ ស្ថាប័នស្រាវជ្រាវ និងបណ្ឌាសាកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧០៩៨ | | ការអប់រំផ្សេងៗ | |
| | | ៧០៩៨០ | ការអប់រំផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការងារអប់រំ ដូចជា÷ ការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការផ្តល់អាជ្ញាប័ណ្ណដល់ស្ថាប័នអប់រំ ការសម្របសម្រួល ការត្រួតពិនិត្យ ដំណើរការ គោល-នយោបាយ ផែនការ កម្មវិធី ឬ ថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីការអប់រំ<br>+រួមបញ្ចូលទាំង÷ សេវា និងការងារអប់រំ ដែលមិនអាចកំណត់ក្នុង ៧០៩១, ៧០៩២, ៧០៩៣, ៧០៩៤, ៧០៩៥, ៧០៩៦ ឬ ៧០៩៧។ |
| ៧១០ | | | ការគាំពារពីសង្គម | |
| | ៧១០១ | | អ្នកជំងឺ របួស និងអ្នកបាត់បង់សមត្ថភាពការងារ | |
| | | ៧១០១១ | អ្នកជំងឺ ឬ របួស | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គមសម្រាប់អ្នកជំងឺ ឬ របួសជាបណ្តោះអាសន្ន អាចជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់ |
| | | ៧១០១២ | អ្នកបាត់បង់សមត្ថភាពការងារ | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គម ជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់ សម្រាប់អ្នកពិការដែលមិនអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច អាចពិការខាងកាយសម្បទា ឬ សតិបញ្ញា<br>+មិនរួមបញ្ចូល÷ អត្ថប្រយោជន៍ជាសាច់ប្រាក់ និងអត្ថប្រយោជន៍ជាសម្ភារ ជូនទៅជនពិការដែលចូលនិវត្តន៍ ដែលបានកំណត់នៅក្នុង ៧១០២០។ |

| | | | | |
|---|---|---|---|---|
| | ៧១០២ | | ចាស់ជរា និងនិវត្តជន | |
| | | ៧១០២០ | ចាស់ជរា និងនិវត្តជន | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គម ជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់សម្រាប់ចាស់ជរា និងនិវត្តជន(អ្នកបាត់បង់ប្រាក់ចំណូល អ្នកមានប្រាក់ចំណូលមិនគ្រប់គ្រាន់ ឬ អ្នកដែលអាចចូលរួមក្នុងជីវភាពសង្គម និងសហគមន៍តិចតួច។ល។)<br>+រួមបញ្ចូលទាំង÷ គម្រោងសោធននិវត្តន៍សម្រាប់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការ<br>+មិនរួមបញ្ចូល÷ អ្នកបាត់បង់សមត្ថភាពការងារ ដែលបានកំណត់នៅក្នុង ៧១០១២ ឬ ភាពអត់ការងារធ្វើ ដែលបានកំណត់នៅក្នុង ៧១០៥០។ |
| | ៧១០៣ | | អ្នកនៅរស់ | |
| | | ៧១០៣០ | អ្នកនៅរស់ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្រគម្រោងគាំពារពីសង្គម ជាអត្ថប្រយោជន៍អាចជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់សម្រាប់អ្នកនៅរស់ ដែលមានសាច់ញាតិស្លាប់ (ដូចជាប្តី/ប្រពន្ធ កូន ចៅ ឪពុកម្តាយ ឬ សាច់ញាតិផ្សេងទៀត) ដើម្បីឱ្យអ្នកនៅរស់មានលទ្ធភាពចូលរួមក្នុងសកម្មភាពសង្គម ឬ សហគមន៍។ |
| | ៧១០៤ | | គ្រួសារ និងកូន | |
| | | ៧១០៤០ | គ្រួសារ និងកូន | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គម ជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ដូចជា÷ ប្រាក់ឧបត្ថម្ភលំហែមាតុភាព ប្រាក់ឧបត្ថម្ភដល់កំណើតកូន គ្រួសារដែលមានតែឪពុក/ម្តាយ ឬ គ្រួសារដែលមានកូនពិការ។ល។ ឬ អត្ថប្រយោជន៍ជាសម្ភារ ដូចជា÷ ជម្រក សេវា និងទំនិញផ្សេងៗដែលផ្តល់សម្រាប់ដល់គ្រួសារដែលត្រូវការជំនួយពីសង្គម<br>+មិនរួមបញ្ចូល÷ សេវារៀបចំផែនការគ្រួសារ ៧០៧៤០។ |
| | ៧១០៥ | | ភាពអត់ការងារធ្វើ | |
| | | ៧១០៥០ | ភាពអត់ការងារធ្វើ | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គមសម្រាប់អ្នកដែលអាចមានសមត្ថភាពធ្វើការ-បាន ប៉ុន្តែមិនអាចរកការងារសមស្របធ្វើបាន អាចជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ដូចជា÷ អត្ថប្រយោជន៍ដែលសង្គមជួយពេញលេញ និងមិនពេញលេញ ការចូលនិវត្តន៍មុនអាយុកំណត់។ល។ ឬ អត្ថប្រយោជន៍ជាសម្ភារ ដូចជា÷ ការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបុគ្គលដែលមិនមានការងារធ្វើ ការផ្តល់កន្លែងស្នាក់នៅ ម្ហូបអាហារ ឬ សំលៀកបំពាក់ទៅឱ្យអ្នកគ្មានការងារធ្វើ និងក្រុមគ្រួសារ។ល។ |

| | | | | |
|---|---|---|---|---|
| | | | | +មិនរួមបញ្ចូល÷ កម្មវិធីទូទៅ ឬ គម្រោងផែនការក្នុងគោលដៅបង្កើនការងារ កាត់បន្ថយអត្រាគ្មានការងារធ្វើ ដែលបានកំណត់នៅក្នុង ៧០៤១២ អត្ថប្រយោជន៍ជាសាច់ប្រាក់ និងជាសម្ភារ ដល់មនុស្សអត់ការងារធ្វើ ហើយដល់អាយុចូលនិវត្តន៍ ដែលបានកំណត់នៅក្នុង ៧១០២០។ |
| | ៧១០៦ | | លំនៅស្ថាន | |
| | | ៧១០៦០ | លំនៅស្ថាន | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្រគម្រោងគាំពារពីសង្គមនៅក្នុងទម្រង់ជាអត្ថប្រយោជន៍ជាសម្ភារ ដើម្បីជួយឱ្យក្រុមគ្រួសារដែលមិនមានលំនៅស្ថានសមរម្យ ដូចជា÷ ការជួយថ្លៃឈ្នួលផ្ទះ ឬ គម្រោងលក់ផ្ទះក្នុងតម្លៃមួយសមរម្យ។ល។ |
| | ៧១០៧ | | ការមិនបានចូលរួមក្នុងសកម្មភាពសង្គម | |
| | | ៧១០៧០ | ការមិនបានចូលរួមក្នុងសកម្មភាពសង្គម | -ការគ្រប់គ្រង ដំណើរការ ឬ ការគាំទ្រគម្រោងគាំពារពីសង្គម សម្រាប់អ្នកដែលមិនអាចចូលរួមក្នុងសកម្មភាពសង្គមបានដូចជា ទុរគតជន ជនអន្តោប្រវេសន៍ ជនជាតិដើមភាគតិច អ្នករកសិទ្ធិជ្រកកោន អ្នកញៀនថ្នាំ ជនរងគ្រោះពីអំពើឧក្រិដ្ឋកម្ម។ល។ ជាអត្ថប្រយោជន៍ជាសាច់ប្រាក់ ដូចជា÷ ការឧបត្ថម្ភបន្ថែមលើប្រាក់-ចំណូល និងចំណាយជាសាច់ប្រាក់ផ្សេងទៀត ឬ អត្ថប្រយោជន៍ជាសម្ភារដូចជា÷ ការផ្តល់កន្លែងស្នាក់នៅ ម្ហូបអាហារ ឬ សំលៀកបំពាក់។ល។ |
| | ៧១០៨ | | ការស្រាវជ្រាវ និងអភិវឌ្ឍគាំពារពីសង្គម | |
| | | ៧១០៨០ | ការស្រាវជ្រាវ និងអភិវឌ្ឍគាំពារពីសង្គម | -កិច្ចការដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍគាំពារពីសង្គម<br>- ហិរញ្ញប្បទានសហប្រតិបត្តិការ ឬ ឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍគាំពារពីសង្គមដែលផ្តល់ដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា÷ ស្ថាប័នស្រាវជ្រាវ និងបណ្ឌាសាកលវិទ្យាល័យនានា<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន ដែលបានកំណត់នៅក្នុង ៧០១៤០។ |
| | ៧១០៩ | | ការគាំពារពីសង្គមផ្សេងៗ | |
| | | ៧១០៩០ | ការគាំពារពីសង្គមផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការគាំពារពីសង្គម ដូចជា÷ ការគ្រប់គ្រងរដ្ឋបាល ការរៀបចំបទប្បញ្ញត្តិ ការសម្របសម្រួល ការត្រួតពិនិត្យ ដំណើរការ គោលនយោបាយ ផែនការ កម្មវិធី ឬ ថវិកា<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីការគាំពារពីសង្គម |

| | | | | |
|---|---|---|---|---|
| | | | | +រួមបញ្ចូលទាំង÷ ការផ្តល់ការគាំពារពីសង្គមនៅក្នុងទម្រង់ជាអត្ថប្រយោជន៍ជាសាច់ប្រាក់ និងអត្ថប្រយោជន៍ជាសម្ភារ ដល់ជនរងគ្រោះដោយសារអគ្គិភ័យ គ្រោះទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗ ដូចជា÷ ការទិញ ការស្តុកទុកអាហារ សម្ភារ និងការផ្គត់ផ្គង់ផ្សេងៗទៀត សម្រាប់ការប្រើប្រាស់ជាបន្ទាន់ដែលមិនអាចកំណត់ក្នុង ៧១០១, ៧១០២, ៧១០៣, ៧១០៤, ៧១០៥, ៧១០៦, ៧១០៧ ឬ ៧១០៨។ |